№ 43

23-11-97

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * * * * *

ឆ្នាំទី ៥ លេខ ៤៣ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្ដាហ៍

ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១- ព្រះរាជក្រម


១៨-១១-១៩៩៧ -ព្រះរាជក្រម ជស/រកម/១១៩៧/០៧ ច្បាប់ស្តីពីគណបក្សនយោបាយ ២៤៦៤


### ២-ព្រះរាជក្រឹត្យ


១៨-១១-១៩៩៧ -ព្រះរាជក្រឹត្យ នស/រកត/១១៩៧/៧២ បន្ថយរយៈពេលរងទោសជាប់ពន្ធនាគារ អោយទណ្ឌិត ២៤៧៦

១៩-១១-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៤៦ តែងតាំងឯកឧត្តម ឧត្តមសេនីយ៍ទោ ជា មិន ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ ២៤៨៤

១៩-១១-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៤៧ តែងតាំងឯកឧត្តម ឧត្តមសេនីយ៍ត្រី នាង ផាត ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ ២៤៨៥

១៩-១១-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៤៨ តែងតាំងឯកឧត្តម ប៉ាន់ ចន្ត្រា ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ ២៤៨៦

១៩-១១-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៤៩ តែងតាំងឯកឧត្តម ស ឃុន ជាអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២៤៨៧

១៩-១១-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៥០ តែងតាំងឯកឧត្តម ខី តាយី ជាអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២៤៨៨

២០-១១-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៥១ តែងតាំងឯកឧត្តម ជុំ សម្បូ៊ន ជាអនុរដ្ឋលេខាធិការក្រសួងការពារជាតិ ២៤៨៩

២១-១១-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៥២ តែងតាំងឯកឧត្តម ហ៊ូ តាំងអេង ជានាយកវិទ្យាស្ថានជាតិស្ថិតិ ២៤៩០

២១-១១-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៥៣ តែងតាំងឯកឧត្តម ស៊ុំ សន្តិសិទ្ធ ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានផែនការ ២៤៩១

## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ

### ប្រកាស


| | | |
|---|---|---|
| ៨-១១-១៩៩៧ | -អនុក្រឹត្យលេខ ៧៥ អនក្រ.បក ស្តីពីការផ្ទេរឥទាន | ២៤៩២ |
| ០-១១-១៩៩៧ | -អនុក្រឹត្យលេខ ៧៦ អនក្រ.បក ស្តីពីការគ្រប់គ្រងធនធានធម្មជាតិតំបន់ព្រៃកទឹកភរាប នៅក្រុងព្រះសីហនុ | ២៤៩៥ |
| ៩-១១-១៩៩៧ | -អនុក្រឹត្យលេខ ២១៨ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថានាជាតិ | ២៤៩៦ |
| ៩-១១-១៩៩៧ | -អនុក្រឹត្យលេខ ២១៩ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថានាជាតិ | ២៤៩៨ |
| ០-១១-១៩៩៧ | -អនុក្រឹត្យលេខ ២២០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៤៩៩ |
| ០-១១-១៩៩៧ | -អនុក្រឹត្យលេខ ២២១ អនក្រ.តត ស្តីពីការផ្តល់មេដាយសេរីមេត្រី | ២៥០០ |
| ០-១១-១៩៩៧ | -អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពីការផ្តល់មេដាយសេរីមេត្រី | ២៥០១ |
| ០-១១-១៩៩៧ | -អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពីការផ្តល់មេដាយសេរីមេត្រី | ២៥០២ |
| ១-១១-១៩៩៧ | -អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៥០៣ |


## III- ការងារបណ្តាក្រសួង

### ១- ទីស្តីការគណៈរដ្ឋមន្ត្រី

### ប្រកាស


| | | |
|---|---|---|
| ៩-១១-១៩៩៧ | -ប្រកាសលេខ ១៥៥ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៥០៥ |


### ២- ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

### ប្រកាស


| | | |
|---|---|---|
| ៨-១១-១៩៩៧ | -ប្រកាស ១០១៧ ផក.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុន អិលវ៉ាយអេស ភីធីអុ អិលធីឌី តំណាងដោយលោក CHOA YAK THIU សញ្ជាតសិង្ហបុរី បង្កើតរោងចក្រក្លាស្សេ | ២៥០៦ |
| ៩-១១-១៩៩៧ | -ប្រកាស ១០១៨ ផក.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុន សាវ គិញ (អិមអិបឃរ៉ិ) តំណាងដោយលោក HO SIU CHEUNG សញ្ជាតចិនហុងកុង បង្កើតរោងចក្រកាត់សំលៀកបំពាក់ | ២៥០៧ |
| ៩-១១-១៩៩៧ | -ប្រកាស ១០១៩ ផក.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុន ស៊្វយហ្វេង ប៊ីវើតប្ល៉េ អិនធើនប្រាយស៍ តំណាងដោយលោក LU ZHAO HUI សញ្ជាតចិន បង្កើតរោងចក្រផលិតទឹកសណ្តែក | ២៥០៩ |

# ឃ

## ៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

### ប្រកាស


១៩-១១-១៩៩៧ -ប្រកាសលេខ ១៧១ ប្រក. ស្តីពីការបង្កើតមជ្ឈមណ្ឌលពត៌មានវិទ្យាទេសចរណ៍ ២៥១


## ៤- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

### សេចក្តីសំរេច


២១-១១-១៩៩៧ -សេចក្តីសំរេចលេខ ៦៣៨ សសរ.មសព្រក ស្តីពីការបែងចែកនិស្សិតចំនួន ៥៨ នាក់ ដែលទើបបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ២៥១ៈ

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១- ព្រះរាជក្រម

**ព្រះរាជក្រម ជស/រកម/១១៩៧/០៧**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត ជីសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

✧ ✧ ✧ ✧ ✧

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣. ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងអំពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាសអោយប្រើ

ច្បាប់ស្តីពីគណៈបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពីគណៈបក្សនយោបាយ

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

មាត្រា ១.- ច្បាប់នេះមានគោលដៅកំណត់បែបបទ និងល័ក្ខខ័ណ្ឌនៃការបង្កើត ការចុះបញ្ជី និងការធ្វើសកម្មភាពរបស់គណបក្សនយោបាយក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.- គណបក្សនយោបាយ គឺជាក្រុមមនុស្សដែលមានគំនិតនិងឆន្ទៈស្របគ្នា ហើយរួបរួមគ្នាដោយស្ម័គ្រចិត្តតាមកិច្ចសន្យាបង្កើតឡើងនូវអង្គការមួយដែលមានលក្ខណៈអចិន្ត្រៃយ៍ និងស្វ័យភាពដើម្បីចូលរួមក្នុងឆាកនយោបាយជាតិតាមរបបប្រជាធិបតេយ្យសេរីពហុបក្ស ដោយការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ស្របតាមការកំណត់នៃរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធជាធរមាន ។

មាត្រា ៣.- គ្រប់គណបក្សនយោបាយត្រូវមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ ឬទីរួមខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤.- គ្រប់គណបក្សនយោបាយមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលបុព្វសិទ្ធិនិងការយកចិត្តទុកដាក់ដោយស្មើភាពគ្នា ពីរាជរដ្ឋាភិបាលនិងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ។

មាត្រា ៥.- ការចូលជាសមាជិករបស់គណៈបក្សនយោបាយណាមួយ គឺជាការជ្រើសរើសផ្ទាល់ខ្លួនដោយសេរីរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។ គ្មានជនណាម្នាក់មានសិទ្ធិបង្ខិតបង្ខំអោយគេចូលជាសមាជិកគណបក្សនយោបាយណាមួយឡើយ ។

គ្មានជនណាម្នាក់ត្រូវបានគេដកហូតសិទ្ធិក្នុងការអនុវត្តន៍សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ ឬសិទ្ធិវិជ្ជាជីវៈ ដោយសារមូលហេតុជននោះជាសមាជិកឬមិនមែនជាសមាជិករបស់គណៈបក្សនយោបាយណាមួយ ដែលបង្កើតឡើងដោយស្របច្បាប់នោះទេ ។

មាត្រា ៦.- គ្រប់គណបក្សនយោបាយមិនត្រូវធ្វើសកម្មភាពណាមួយ ដូចខាងក្រោមនេះ :

១-ធ្វើអោយមានអបគមន៍ ដែលនាំអោយអន្តរាយដល់ឯកភាពជាតិ និងបូរណភាពដែនដី ។

២-ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យសេរីពហុបក្សដោយប្រើប្រាស់មធ្យោបាយហិង្សាក្នុងគោលបំណងដណ្តើមអំណាច ។

៣-បង្កើតកងកម្លាំងប្រដាប់អាវុធ ។

មាត្រា ៧.- គ្រប់គណបក្សនយោបាយមិនត្រូវស្ថិតនៅក្រោមចំណុះឬការបង្គាប់បញ្ជារបស់គណៈបក្សនយោបាយបរទេសឬរបស់រដ្ឋាភិបាលបរទេស ។

មាត្រា ៨.- ការចុះបញ្ជីគណបក្សនយោបាយជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ២

## ការបង្កើតគណបក្សនយោបាយ

មាត្រា ៩.- ប្រជាពលរដ្ឋខ្មែរចំនួនយ៉ាងតិច ៨០នាក់ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ ហើយដែលមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិផ្តើមបង្កើតគណៈបក្សនយោបាយមួយបាន ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខអក្សរទៅក្រសួងមហាផ្ទៃ។ ក្រសួងមហាផ្ទៃត្រូវឆ្លើយតបជាលាយលក្ខអក្សរថាបានទទួលសេចក្តីជូនដំណឹងនេះ ក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ។ បើហួសការកំណត់១៥ថ្ងៃនេះ ត្រូវចាត់ទុកថាបានទទួលសេចក្តីជូនដំណឹងនេះ ។

គណបក្សនយោបាយដែលទើបផ្តើមបង្កើតត្រូវធ្វើការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការបណ្តោះអាសន្ន[illegible]មានសមាជិកយ៉ាងតិច ៧ រូប ហើយដែលម្នាក់ៗមានអាយុយ៉ាងតិច២៥ឆ្នាំ សម្រាប់រៀបចំបែបបទនិងបំពេញល័ក្ខខ័ណ្ឌនៃការសុំចុះបញ្ជីគណបក្សនយោបាយតាមការកំណត់ដូ[illegible]ក្នុងជំពូកទី៥ នៃច្បាប់នេះ ដើម្បីទទួលសុពលភាព ។

ទោះបីមិនទាន់ទទួលសុពលភាពក៏ដោយ ក្នុងរយៈពេលនេះ គណបក្សនយោបាយអាចលើកផ្លាកនៅទីស្នាក់ការរបស់ខ្លួនបាន ។

មាត្រា ១០.- គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំលក្ខន្តិកៈនិងគោលនយោបាយសំខាន់ៗ ជាលាយលក្ខអក្សរ ដែលមានចំណុចសំខាន់ៗយ៉ាងតិចណាស់ដូចខាងក្រោមនេះ :

ក-លក្ខន្តិកៈត្រូវមាន :

១-ឈ្មោះជាអក្សរពេញ អក្សរកាត់ និងសញ្ញាសំគាល់ ។

២-អាស័យដ្ឋាននៃទីស្នាក់ការកណ្តាល ។

៣-កាលបរិច្ឆេទនៃការបង្កើតគណបក្សនយោបាយ ។ កាលបរិច្ឆេទគណបក្សនយោបាយនេះមិនត្រូវជាន់លើថ្ងៃបុណ្យជាតិ និងអន្តរជាតិ។

៤-វិធានស្តីពីការបញ្ចូលជាសមាជិកភាព និងការបណ្តេញចេញពីសមាជិកភាព។

៥-សិទ្ធិនិងភារកិច្ចរបស់សមាជិក ។

៦-រចនាសម្ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមបន្តបន្ទាប់ ។

៧-សមត្ថកិច្ចនៃអង្គការនានា របស់គណបក្សនយោបាយ ។

២-របៀបនៃការជ្រើសរើសនិងដកហូតមុខងារ របស់សមាជិកគណៈកម្មាធិការនាយក។

៩-ការកំណត់អំពីការប្រជុំសាមញ្ញ នៃអង្គការនានារបស់គណបក្សនយោបាយ។

១០-ចំនួនសមាជិកចាំបាច់ "កូរ៉ុម " ដែលត្រូវចូលរួមក្នុងអង្គប្រជុំនៃអង្គការនានារបស់គណបក្សនយោបាយ ដើម្បីអោយអង្គប្រជុំនោះយកជាការបាន ។

១១-ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់គណបក្សនយោបាយ ។

១២-វិធានស្តីពីការរំលាយគណបក្សនយោបាយ និងការចាត់ចែងទ្រព្យសម្បត្តិរបស់គណបក្សនយោបាយ នៅពេលត្រូវរំលាយ ។

១៣-វិធានស្តីពីការធ្វើវិសោធនកម្មលក្ខន្តិកៈគណបក្សនយោបាយ ។

៦-គោលនយោបាយនិងកម្មវិធីនយោបាយសំខាន់ៗត្រូវចែងអំពីគោលដៅ និងវត្ថុបំណងរបស់គណបក្សនយោបាយ ។

មាត្រា ១១.- គ្រប់គណបក្សនយោបាយត្រូវមានឈ្មោះ និងសញ្ញាសំគាល់តាមការកំណត់ដូចខាងក្រោម :

១-ឈ្មោះជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសំគាល់របស់គណបក្សនយោបាយត្រូវតែខុសគ្នាពីឈ្មោះជាអក្សរពេញឬអក្សរកាត់និងសញ្ញាសំគាល់របស់គណបក្សនយោបាយនានា ។

២-ឈ្មោះរបស់គណបក្សនយោបាយដែលទើបបង្កើតថ្មីមិនត្រូវធ្វើឡើងដោយគ្រាន់តែកែសំរួលបន្តិចបន្តួចនៅលើឈ្មោះគណបក្សនយោបាយនានា ។

៣-សញ្ញាសំគាល់របស់គណបក្សនយោបាយមិនត្រូវចម្លងឬយកតាមសញ្ញាជាតិ រូបភាពតំណាងអោយសាសនា ប្រាសាទអង្គរវត្ត ឬព្រះឆាយាល័ក្ខណ៍ ឬរូបសំណាករបស់ព្រះមហាក្សត្រខ្មែរគ្រប់អង្គ ។

## ជំពូកទី ៣

## សមាជិកភាព

មាត្រា ១២.-ប្រជាពលរដ្ឋខ្មែរដែលមានអាយុយ៉ាងតិច១៨ឆ្នាំ និងមានសិទ្ធិពលរដ្ឋអាចចូលជាសមាជិកគណបក្សនយោបាយបាន ។

មាត្រា ១៣.- ការចូលជាសមាជិកនៃគណបក្សនយោបាយ ត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត។

សមាជិកគណបក្សនយោបាយអាចលាឈប់ពីគណបក្សនយោបាយបានគ្រប់ពេលវេលាដោយមិនបាច់បញ្ជាក់ពីមូលហេតុឡើយ ។

មាត្រា ១៤.- សមាជិកគណបក្សនយោបាយមានសិទ្ធិ ភារកិច្ចដូចគ្នាស្របតាមលក្ខន្តិកៈ នៃគណបក្សនយោបាយ ។

មាត្រា ១៥.- ប្រជាពលរដ្ឋខ្មែរម្នាក់មិនអាចជាសមាជិកគណបក្សនយោបាយលើសពីមួយក្នុងពេលតែមួយបានទេ ។ ក្នុងករណីដែលបុគ្គលមួយរូបចូលជាសមាជិកគណបក្សនានាយ៉ាងច្រើនសមាជិកភាពក្នុងគណបក្សនយោបាយចុងក្រោយត្រូវចាត់ទុកជាបានការ ។

បព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទនិងកងកម្លាំងនគរបាលជាតិ អាចចូលជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រឬប្រឆាំងគណបក្សនយោបាយណាមួយទេ ។

គណបក្សនយោបាយមិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងក្នុងស្ថាប័ន សាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិទេ ។

មាត្រា ១៦.- សមាជិកគណបក្សនយោបាយត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោមនេះ :

១-បានលាឈប់ ឬបានបោះបង់សមាជិកភាពនៃគណបក្សនយោបាយ ។

២-ត្រូវបានបណ្តេញចេញពីគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយសាមី ។

## ជំពូកទី ៤

## អង្គការនានារបស់គណបក្សនយោបាយ

មាត្រា ១៧.- អង្គការដឹកនាំរបស់គណបក្សនយោបាយនីមួយៗ ត្រូវមានយ៉ាងតិចដូចខាងក្រោម:

-មហាសន្និបាត ឬសមាជ ឬអង្គការសមមូល ។

-ក្រុមប្រឹក្សាជាតិ ឬគណៈកម្មាធិការកណ្តាល ឬអង្គការសមមូល ។

-គណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូល ។

-គណៈកម្មាធិការអាជ្ញាកណ្តាល ឬគណៈកម្មាធិការត្រួតពិនិត្យ ឬគណៈកម្មាធិការវិវាទ ឬអង្គការសមមូល ។

ឈ្មោះអង្គការដឹកនាំរបស់គណបក្សនយោបាយគ្រប់ថ្នាក់នេះ អាចប្រែប្រួលអាស្រ័យទៅតាមការកំណត់របស់លក្ខន្តិកៈ នៃគណបក្សនយោបាយនីមួយៗ ។

មាត្រា ១៨.- អាណត្តិ ភារកិច្ច ការរៀបចំនិងការប្រព្រឹត្តិទៅរបស់អង្គការដឹកនាំរបស់គណបក្សនយោបាយនីមួយៗ តាមការកំណត់ដូចមានចែងក្នុងមាត្រា១៧នៃច្បាប់នេះ និងអង្គការនានាទៀតរបស់គណបក្សនយោបាយ ត្រូវកំណត់ក្នុងលក្ខន្តិកៈឬបទបញ្ជាផ្ទៃក្នុង ។

## ជំពូកទី ៥

## ការចុះបញ្ជីគណបក្សនយោបាយ

មាត្រា ១៩.- ដើម្បីទទួលសុពលភាពដូចមានចែងក្នុងវាក្យខ័ណ្ឌទី២ មាត្រា៩ នៃច្បាប់នេះ គណបក្សនយោបាយត្រូវសុំចុះបញ្ជីគណបក្សនយោបាយ ដោយត្រូវមានសមាជិកយ៉ាងតិច ៤០០០ នាក់ មកពីបណ្តាខេត្តក្រុងមួយចំនួន ។

មាត្រា ២០.- គណបក្សនយោបាយ ត្រូវបំពេញបែបបទនិងល័ក្ខខ័ណ្ឌដូចខាងក្រោម :

១-ពាក្យសុំចុះបញ្ជីគណបក្សនយោបាយត្រូវមានហត្ថលេខារបស់ប្រធានគណបក្សនយោបាយ ។

២-ឈ្មោះជាអក្សរពេញ និងអក្សរកាត់ និងសញ្ញាសំគាល់របស់គណបក្សនយោបាយ។

៣-អាស័យដ្ឋាន នៃទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ ។

៤-ច្បាប់ដើមនៃលក្ខន្តិកៈ គណៈបក្សនយោបាយចំនួនពីរច្បាប់ ។

៥-បទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយ ប្រសិនបើមាន ។

៦-គោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗ របស់គណបក្សនយោបាយ ។

៧-សេចក្តីថ្លែងការជាលាយលក្ខអក្សររបស់គណបក្សនយោបាយស្តីពីការគោរពរដ្ឋធម្មនុញ្ញច្បាប់ស្តីពីគណបក្សនយោបាយនិងបទប្បញ្ញត្តិផ្សេងៗជាធរមាន និងគោលការណ៍នៃលិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស ។

៨-បញ្ជីឈ្មោះ ដោយមានអាយុ អាស័យដ្ឋាននិងស្នាមមេដៃរបស់សមាជិកទាំង ៤០០០ នាក់ ដោយមានបញ្ជាក់លេខប័ណ្ណសមាជិកគណបក្ស និងកាលបរិច្ឆេទនៃការចូលសមាជិកភាពគណបក្សនយោបាយ ។

៩-ជីវប្រវត្តិសង្ខេបរបស់ប្រធាន ឬស្ថាបនិកចំនួន៣នាក់យ៉ាងតិចក្នុងមួយនាក់មួយច្បាប់ ដោយមានបិទរូបថតទំហំ ៤ គុណនឹង ៦ ។

១០-សេចក្តីប្រកាសអំពីគណនីធនាគារ នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ។

១១-បង្កាន់ដៃថ្លៃអាករចុះបញ្ជីគណបក្សនយោបាយមួយច្បាប់។ ថ្លៃអាករនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ២១.- ក្រសួងមហាផ្ទៃត្រូវចេញបង្កាន់ដៃទទួលពាក្យសុំមួយច្បាប់ អោយគណបក្សនយោបាយដែលបានបំពេញទម្រង់បែបបទគ្រប់គ្រាន់ តាមការកំណត់ដូចមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ។

មាត្រា ២២.- ក្រសួងមហាផ្ទៃត្រូវពិនិត្យខ្លឹមសារនៃសំណុំឯកសាររបស់គណបក្សនយោបាយ បន្ទាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យសុំ ដូចមានចែងក្នុងមាត្រា២១នៃច្បាប់នេះ។

ក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃ ក្រសួងមហាផ្ទៃត្រូវសម្រេចយល់ព្រមឬមិនយល់ព្រមអោយចុះបញ្ជីគណបក្សនយោបាយ។

មាត្រា [illegible] - ក្នុងករណីពិនិត្យឃើញថា សំណុំឯកសាររបស់គណបក្សនយោបាយពុំមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយនិងច្បាប់នានាជាធរមាន

ក្រសួងមហាផ្ទៃត្រូវធ្វើលិខិតឆ្លើយតបស្តីពីការយល់ព្រមអោយចុះបញ្ជី ផ្ញើជូនទៅសាមីគណបក្សនយោបាយនោះវិញ ដោយភ្ជាប់ជាមួយនូវលក្ខន្តិកៈមួយច្បាប់ ដែលមានចារបញ្ជាក់កាលបរិច្ឆេទ នៃការចុះបញ្ជីគណបក្សនយោបាយ ដោយមានចុះហត្ថលេខានិងត្រារបស់ក្រសួងមហាផ្ទៃ។

មាត្រា ២៤.- ក្នុងករណីពិនិត្យឃើញថា សំណុំឯកសាររបស់គណបក្សនយោបាយ ដែលមិនទាន់មានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយនិងច្បាប់នានាជាធរមាន ក្រសួងមហាផ្ទៃត្រូវធ្វើលិខិតជូនដំណឹងផ្ញើជូនទៅសាមីគណបក្សនយោបាយនេះវិញ ។ គណបក្សនយោបាយនោះត្រូវបំពេញបន្ថែមលើសំណុំឯកសារតាមលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃយ៉ាងយូរ ១៥ថ្ងៃ ចាប់ពីថ្ងៃទទួលលិខិតនេះ ។ បើហួសរយៈពេលកំណត់ ១៥ថ្ងៃនេះ ក្រសួងមហាផ្ទៃ ត្រូវធ្វើលិខិតមិនយល់ព្រមអោយចុះបញ្ជីគណៈបក្សនយោបាយផ្ញើជូនទៅសាមីគណបក្សនយោបាយ ។

មាត្រា ២៥.- គណៈបក្សនយោបាយណា ដែលក្រសួងមហាផ្ទៃបានចេញលិខិតមិនយល់ព្រមអោយចុះបញ្ជីគណបក្សនយោបាយ ដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ គណបក្សនយោបាយនោះមានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងរបស់សាមីគណបក្សនយោបាយនោះ។

ក្រោយពីបានទទួលសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលសំរេចលើភាពត្រឹមត្រូវនៃខ្លឹមសារនៃសំណុំឯកសាររបស់គណៈបក្សនយោបាយនោះ ក្រសួងមហាផ្ទៃត្រូវចុះបញ្ជីគណបក្សនយោបាយនោះភ្លាម តាមការកំណត់ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ។

មាត្រា ២៦.- គណៈបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ អាចប្តូរឈ្មោះឬកែប្រែគោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗឬធ្វើវិសោធនកម្មលើលក្ខន្តិកៈបានស្របតាមលក្ខន្តិកៈរបស់គណៈបក្សនយោបាយខ្លួន។ ក្នុងករណីនេះ គណបក្សនយោបាយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃដោយភ្ជាប់មកជាមួយនូវសំណុំឯកសារថ្មីដែលកែប្រែរួចហើយ ។ ដោយឡែកការផ្លាស់ប្តូរ[illegible]ានគណបក្សនយោបាយត្រូវជូនដំណឹងជាលា[illegible]អក្សរមកក្រសួង មហាផ្ទៃ

ដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេបរបស់ប្រធានថ្មីដោយមានបិទរូបថត ទំហំ ៤ គុណ និង ៦ ។

## ជំពូកទី ៦

## ហិរញ្ញវត្ថុរបស់គណបក្សនយោបាយ

មាត្រា ២៧.- ចាត់ទុកជាហិរញ្ញវត្ថុរបស់គណបក្សនយោបាយ ចំណូលដែលបានមកពី :

១-វិភាគទាន ឬភាគទានរបស់សមាជិក ។

២-ចំណូលផ្សេងៗរបស់គណបក្សនយោបាយដែលបានមកពីការធ្វើអាជីវកម្មស្របច្បាប់។

៣-ប្រាក់ពីថវិការបស់រដ្ឋតាមការកំណត់ ដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ ។

៤-អំណោយរបស់ក្រុមហ៊ុនឯកជនខ្មែរ ឬសប្បុរសជនខ្មែរ ។

៥-ទ្រព្យសម្បត្តិផ្ទាល់របស់គណបក្សនយោបាយ ។

មាត្រា ២៨.- រដ្ឋអាចផ្តល់ប្រាក់ពីថវិកាជាតិស្មើៗគ្នា ដល់គ្រប់គណបក្សនយោបាយសំរាប់តែប្រើប្រាស់ក្នុងយុទ្ធនាការ ឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

គណបក្សនយោបាយណា ដែលមិនបានទទួលសន្លឹកឆ្នោតគាំទ្រចំនួន៣%នៃសន្លឹកឆ្នោតបានការសរុបទូទាំងប្រទេសឬមិនបានទទួលអាសនៈមួយក្នុងសភា គណបក្សនយោបាយនោះត្រូវសងប្រាក់នោះគ្រប់ចំនួនមករដ្ឋវិញក្នុងរយៈពេល ៣ខែយ៉ាងយូរ ចាប់ពីថ្ងៃប្រកាសលទ្ធផលជាស្ថាពរនៃការបោះឆ្នោត ។

មាត្រា ២៩.- គណបក្សនយោបាយត្រូវបានហាមឃាត់មិនអោយទទួលវិភាគទាន ទោះជាតាមរូបភាពណាក៏ដោយ ពីស្ថាប័នរដ្ឋ សមាគម អង្គការក្រៅរដ្ឋាភិបាល សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ វិទ្យាស្ថានសាធារណៈឬក្រុមហ៊ុនបរទេស លើកលែងតែករណីដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ ។

## ជំពូកទី ៧

## របាយការណ៍និងការត្រួតពិនិត្យ

មាត្រា ៣០.- របាយការណ៍និងឯកសារពាក់ព័ន្ធនឹងគណនេយ្យ ត្រូវតម្កល់ទុករយៈពេលយ៉ាងតិច ៧ឆ្នាំ ហើយអាចអនុញ្ញាតអោយត្រួតពិនិត្យ ដោយអនុលោមតាមលក្ខន្តិកៈឬបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយឬការសំរេចរបស់តុលាការឬស្ថាប័នមានសមត្ថកិច្ច ។

មាត្រា ៣១.-គណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយរួចហើយ ត្រូវផ្ញើរបាយការណ៍មកក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយបានមុនថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។ របាយការណ៍ត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ និងហិរញ្ញិក។

របាយការណ៍នេះ ត្រូវមានខ្លឹមសារនិងឯកសារដូចខាងក្រោម :

១-សកម្មភាពសំខាន់ៗ របស់គណបក្សនយោបាយ ។

២-តារាងតុល្យភាពដែលបង្ហាញនូវប្រាក់ចំណូលនិងប្រាក់ចំណាយប្រចាំឆ្នាំតាមប្រភេទ។ តារាងតុល្យភាពនេះ ត្រូវរៀបចំឡើងដោយគណនេយ្យរបស់គណបក្សនយោបាយ ។

៣-បញ្ជីតុល្យការគណនីរបស់គណបក្សនយោបាយនៅក្នុងធនាគារ ។

៤-បញ្ជីតុល្យការនៃទ្រព្យសម្បត្តិទាំងអស់ រាប់បញ្ចូលទាំងទ្រព្យសម្បត្តិជាកម្មសិទ្ធិឬផលកម្រៃក្នុងជំនួញនិងបំណុលរបស់គណបក្សនយោបាយ។

មាត្រា ៣២.- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវក្នុងការពិនិត្យបញ្ជីតុល្យការទាំងឡាយដែលមានចែងក្នុងចំណុច ២.៣.៤ មាត្រា ៣១ នៃច្បាប់នេះ ។

## ជំពូកទី ៨

## ការរំលាយ ការរួមបញ្ចូលគ្នានិងការធ្វើសម្ព័ន្ធភាពគណបក្សនយោបាយ

មាត្រា ៣៣.- គណបក្សនយោបាយអាចរំលាយខ្លួនឯងបាន តាមសេចក្តីសំរេចរបស់មហាសន្និបាត ដោយអនុលោមតាមលក្ខន្តិកៈរបស់ខ្លួន បន្ទាប់ពីបានធ្វើការជំរះបញ្ជីនិងចាត់ចែងទ្រព្យ សម្បត្តិរបស់គណបក្សនយោបាយ ។ គណបក្សនយោបាយត្រូវជូនដំណឹងជាលាយលក្ខអក្សរ ពីការរំលាយនេះដល់ក្រសួងមហាផ្ទៃភ្លាម ដើម្បីលុបឈ្មោះគណបក្សនយោបាយនោះចេញ ពីបញ្ជីគណបក្សនយោបាយ ។

មាត្រា ៣៤.- គ្មានសមត្ថកិច្ចណាមានសិទ្ធិរំលាយគណបក្សនយោបាយណាមួយបានឡើយ លើកលែងតែគណបក្សនយោបាយនោះត្រូវបានប្រកាសរំលាយតាមសាលក្រមឬសាលដីកាជាស្ថាពររបស់តុលាការ ។

មាត្រា ៣៥.- គណបក្សនយោបាយដែលត្រូវបានប្រកាសរំលាយដូចមានចែងក្នុងមាត្រា៣៣ នៃច្បាប់នេះ ការចាត់ចែងទ្រព្យសម្បត្តិដែលនៅសេសសល់ ត្រូវអនុវត្តតាមសេចក្តីសំរេចរបស់មហាសន្និបាត ។

មាត្រា ៣៦.-គណបក្សនយោបាយអាចប្រកាសរួមបញ្ចូលគ្នាជាមួយគណបក្សនយោបាយផ្សេងទៀតបាន តាមការកំណត់របស់លក្ខន្តិកៈ ។ ក្នុងករណីដែលលក្ខន្តិកៈមិនបានចែង ត្រូវអនុវត្តតាមសេចក្តីសំរេចរបស់មហាសន្និបាតគណបក្សនយោបាយ ។

ក្រសួងមហាផ្ទៃត្រូវលុបឈ្មោះគណបក្សនយោបាយដែលបានប្រកាសរួមបញ្ចូលគ្នានោះចេញពីបញ្ជីគណបក្សនយោបាយ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីការរួមបញ្ចូលនោះ។

មាត្រា ៣៧.- គណបក្សនយោបាយអាចធ្វើសម្ព័ន្ធភាពទ្វេភាគី ឬ ពហុភាគីជាមួយគ្នាបានដោយសេរីតាមសេចក្តីសំរេចរបស់គណបក្សនយោបាយនីមួយៗ ។

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

មាត្រា ៣៨.- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនបីលានរៀល (៣.០០០.០០០រៀល) ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៣១ នៃច្បាប់នេះ។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេមួយជាពីរហើយអាចផ្តន្ទាទោសផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្ន ។

មាត្រា ៣៩.- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី បីលានរៀល (៣.០០០.០០០រៀល) ដល់ ប្រាំលានរៀល (៥.០០០.០០០ រៀល) ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៧ និង មាត្រា២៩ នៃច្បាប់នេះ។

ក្នុងករណីមិនរាងចាល [illegible] ទោសពិន័យជាប្រាក់ទ្វេមួយជាពីរ ហើយអាចផ្អាកសកម្មភាពគណបក្សនយោបាយនោះជា[illegible]ណ្តោះអាសន្ន ។

មាត្រា ៤០.- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួន មួយលានរៀល (១.០០០.០០០រៀល) ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ និងវាក្យខណ្ឌទី ២ នៃមាត្រា ១៥ នៃច្បាប់នេះ ។

មាត្រា ៤១.- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី មួយលានរៀល (១.០០០.០០០រៀល) ដល់ប្រាំលានរៀល (៥.០០០.០០០ រៀល) និងឬផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ដល់ ១ឆ្នាំ ចំពោះជនណាដែលបានប្រព្រឹត្តដូចខាងក្រោម :

១-បន្តគ្រប់គ្រង ដឹកនាំគណបក្សនយោបាយ ដែលក្រសួងមហាផ្ទៃមិនយល់ព្រមអោយចុះក្នុងបញ្ជីគណបក្សនយោបាយ ឬ

២-បន្តគ្រប់គ្រង ដឹកនាំគណបក្សនយោបាយដែលតុលាការបានចេញសាលក្រម ឬសាលដីកាជាស្ថាពររំលាយរួចហើយ ឬ

៣-គ្រប់គ្រងដឹកនាំគណបក្សនយោបាយដោយមិនបានសុំចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយក្នុងរយៈពេលលើសពី ១៨ខែ គិតចាប់តាំងពីថ្ងៃធ្វើការបោះឆ្នោតជ្រើសតាំង គណៈកម្មាធិការបណ្ដោះអាសន្នដូចមានចែងក្នុងមាត្រា៩នៃច្បាប់នេះឬ

៤-នៅតែបន្តបើកទីស្នាក់ការគណបក្សនយោបាយខ្លួន ទោះជាមានសាលក្រម ឬសាលដីកាជាស្ថាពររបស់តុលាការសំរេចរំលាយឬផ្អាកសកម្មភាពគណបក្សនយោបាយនោះក៏ដោយ។

មាត្រា ៤២.- ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៦នៃច្បាប់នេះ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ១០

## អន្តរប្បញ្ញត្តិ

មាត្រា ៤៣.- បន្ទាប់ពីច្បាប់នេះចូលជាធរមាន គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីគណបក្សនយោបាយតាមការកំណត់របស់អនុក្រឹត្យឆ្នាំ១៩៩៣ ត្រូវបញ្ជូនសំណុំឯកសារតាមការកំណត់ដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់នេះ លើកលែងតែចំណុចទី ១១ មកតម្កល់ទុកនៅក្រសួងមហាផ្ទៃវិញ ក្នុងរយៈពេល៩០ថ្ងៃយ៉ាងយូរ ។ បើហួសរយៈពេលដូចបានកំណត់ខាងលើនេះ ត្រូវចាត់ទុកថាគណបក្សនយោបាយនោះ បានបោះបង់ការចុះបញ្ជីគណបក្សនយោបាយ ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

មាត្រា ៤៤.- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤៥.- ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសព្វព្រះរាជហឫទ័យ

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

បានជំរាបជូន នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ ហត្ថលេខា និងត្រា

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អ៊ឹង ហួត ហ៊ុន សែន

ហត្ថលេខា

ស ខេង យូ ហុកគ្រី

===

## ២-ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស.រកត.១០៩៧.៧២

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះ..ជ្រូវកម្ពុជាធិបតី

* * * * *

បានទ្រង់យល់រដ្ឋធម្ម ្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី២០.៦.៨៨

* * * * *

### ទ្រង់ត្រាស់បង្គាប់

មាត្រា ១.-ត្រូវបន្ថយរយៈពេលទទួលរងទោសជាប់ពន្ធនាគារពីអស់មួយជីវិតមកត្រឹម ២០ឆ្នាំ អោយទណ្ឌិតចំនួន ១ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានឈ្មោះខាងក្រោម :

១-ទណ្ឌិតឈ្មោះ ឡឹត ឃន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់អស់មួយជីវិត តាមអំណាចសាលក្រមលេខ៥ ចុះថ្ងៃទី៧ ខែ១០ ឆ្នាំ១៩៨៤ របស់តុលាការខេត្តតាកែវ។

មាត្រា ២.-ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន១២ខែ អោយទណ្ឌិតចំនួន ១០ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមាន រាយឈ្មោះខាងក្រោម :

១-ទណ្ឌិតឈ្មោះ ផង់ មាង់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់២០ ឆ្នាំ តាមអំណាចសាលក្រមលេខ០១ ចុះថ្ងៃទី១១ ខែ៤ ឆ្នាំ១៩៨៨ របស់តុលាការខេត្តកណ្តាល។

២-ទណ្ឌិតឈ្មោះ អ៊ិន ផល្លី ហៅ អត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ៣៩ ចុះថ្ងៃទី២៣ ខែ៨ ឆ្នាំ១៩៩៣ របស់តុលាការខេត្តកណ្តាល ។

៣-ទណ្ឌិតឈ្មោះ ស៊ុំ តី ហៅ ស៊ុំ ធី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ៤២ ចុះថ្ងៃទី២៧ ខែ៨ ឆ្នាំ ១៩៩៣ របស់តុលាការខេត្តកណ្តាល ។

៤-ទណ្ឌិតឈ្មោះ វ៉ន រី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៤ ចុះថ្ងៃទី៨ ខែ៤ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកណ្តាល ។

៥-ទណ្ឌិតឈ្មោះ ជុំច អ៊ុយ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ០៤ ចុះថ្ងៃទី២៥ ខែ៥ ឆ្នាំ១៩៨៨ របស់តុលាការខេត្តកណ្តាល ។

៦-ទណ្ឌិតឈ្មោះ ខិន យឿម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី១៧ ខែ១០ ឆ្នាំ១៩៩១ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៧-ទណ្ឌិតឈ្មោះ ឆិត លី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី២៣ ខែ៦ ឆ្នាំ១៩៨៧ របស់តុលាការ ខេត្តកណ្តាល ។

៨-ទណ្ឌិតឈ្មោះ សួន សារឿន ហៅ ភឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ ចុះថ្ងៃទី៨ ខែ៩ ឆ្នាំ១៩៨៦ របស់តុលាការខេត្តកណ្តាល ។

៩-ទណ្ឌិតឈ្មោះ គីម សារិន ហៅ គេម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់២០ឆ្នាំ តាមអំណាចសាលក្រមលេខ០៥ ចុះថ្ងៃទី៣០ ខែ១០ ឆ្នាំ១៩៨៧ របស់តុលាការខេត្តតាកែវ។

១០-ទណ្ឌិតឈ្មោះ យ៉ះ គី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី២១ ខែ៦ ឆ្នាំ១៩៨៥ របស់តុលាការខេត្តតាកែវ ។

មាត្រា ៣.-ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន៩ ខែ អោយទណ្ឌិតចំនួន២១ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះ ខាងក្រោម :

១-ទណ្ឌិតឈ្មោះ ម៉ៃ ថា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៤ឆ្នាំ តាមអំណាចសាលក្រមលេខ៦៤ ចុះថ្ងៃទី២៦ ខែ១២ ឆ្នាំ១៩៩៣របស់តុលាការខេត្តកណ្តាល ។

២-ទណ្ឌិតឈ្មោះ ពួន ចយ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១២ឆ្នាំតាមអំណាចសាលក្រមលេខ ៥ ចុះថ្ងៃទី៦ ខែ៥ ឆ្នាំ១៩៩៣ របស់តុលាការខេត្តកណ្តាល។

៣-ទណ្ឌិតឈ្មោះ ជ៉ិន មុំ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ ចុះថ្ងៃទី១៤ ខែ៥ ឆ្នាំ១៩៩៣ របស់តុលាការ ខេត្តកណ្តាល ។

៤-ទណ្ឌិតឈ្មោះ ឡុច ឈិត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ ចុះថ្ងៃទី៣ ខែ៣ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកណ្តាល ។

៥-ទណ្ឌិតឈ្មោះ ហ៊ុយ សុខ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអណាចសាលក្រមលេខ៦៦ ចុះថ្ងៃទី២៨ ខែ១២ ឆ្នាំ១៩៩៣ របស់តុលាការខេត្តកណ្តាល។

៦-ទណ្ឌិតឈ្មោះ សី ពៅ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៤ឆ្នាំ តាមអំណាចសាលក្រមលេខ១០៧ ចុះថ្ងៃទី១២ ខែ៥ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកណ្តាល។

៧-ទណ្ឌិតឈ្មោះ សោខ ទ្រី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ ចុះថ្ងៃទី២០ ខែ៦ ឆ្នាំ១៩៩១ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៨-ទណ្ឌិតឈ្មោះ ជា រស់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី២២ ខែ០១ ឆ្នាំ១៩៩១ របស់តុលាការខេត្តបន្ទាយមានជ័យ។

៩-ទណ្ឌិតឈ្មោះ និត ឈេត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី២៣ ខែ៩ ឆ្នាំ១៩៩២ របស់តុលាការខេត្តបន្ទាយមានជ័យ។

១០-ទណ្ឌិតឈ្មោះ សី ធូ ហៅ ថាញ់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ២៨ ចុះថ្ងៃទី ២៤ ខែ ៩ ឆ្នាំ ១៩៩២ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១១-ទណ្ឌិតឈ្មោះ សំរ៉េង សំបូរ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦ ចុះថ្ងៃទី២៩ ខែ៦ ឆ្នាំ១៩៩២ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១២-ទណ្ឌិតឈ្មោះ ឈា រ៉េម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៤ ឆ្នាំ តាមអណាចំសាលក្រមលេខ២៣ ចុះថ្ងៃទី២២ ខែ៩ ឆ្នាំ១៩៩២ របស់តុលាការ ខេត្តបន្ទាយមានជ័យ។

១៣-ទណ្ឌិតឈ្មោះ ឆាយ សុវណ្ណ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ តាមអំណាចសាលក្រមលេខ១៥ ចុះថ្ងៃទី២៧ ខែ៦ ឆ្នាំ១៩៩២ របស់តុលាការខេត្តបន្ទាយមានជ័យ។

១៤-ទណ្ឌិតឈ្មោះ ខណ្ឌ មេឧ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី២៦ ខែ០១ ឆ្នាំ១៩៩៥ របស់តុលាការ ខេត្តតាកែវ ។

១៥-ទណ្ឌិតឈ្មោះ វឿន ថន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩ ចុះថ្ងៃទី២១ ខែ៦ ឆ្នាំ១៩៩១ របស់តុលាការ ខេត្តបន្ទាយមានជ័យ។

១៦-ទណ្ឌិតឈ្មោះ ឯម ហោ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី១២ ខែ៤ ឆ្នាំ១៩៩៤ របស់តុលាការ ខេត្តតាកែវ ។

១៧-ទណ្ឌិតឈ្មោះ ជុច ឌៃ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ១៨៦ ចុះថ្ងៃទី៣០ ខែ៧ ឆ្នាំ១៩៩៤ របស់តុលាការ ខេត្តកណ្តាល។

១៨-ទណ្ឌិតឈ្មោះ ស៊ូ អ៊ិនអ៊ីច ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៥ឆ្នាំ តាមអំណាចសាលក្រមលេខ៣ ចុះថ្ងៃទី២៣ ខែ៨ ឆ្នាំ១៩៩១ របស់តុលាការ ខេត្តតាកែវ។

១៩-ទណ្ឌិតឈ្មោះ អ៊ិ ឃុន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី៧ ខែ៩ ឆ្នាំ១៩៨៨ របស់តុលាការ ខេត្តតាកែវ ។

២០-ទណ្ឌិតឈ្មោះ ខយ ឃោត ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់១២ ឆ្នាំ តាមអំណាចសាលក្រមលេខ៣ ចុះថ្ងៃទី២០ ខែ៧ ឆ្នាំ១៩៩៣ របស់តុលាការ ខេត្តតាកែវ ។

២១-ទណ្ឌិតឈ្មោះ ម៉ុស ចាន់ឌិប្លូស ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ ចុះថ្ងៃទី២៣ ខែ៥ ឆ្នាំ១៩៩៤ របស់តុលាការ ខេត្ត ក្រចេះ ។

មាត្រា ៤.- ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ អោយទណ្ឌិតចំនួន ៣២ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក. ដូចមានរាយឈ្មោះខាងក្រោម៖

១-ទណ្ឌិតឈ្មោះ វៃ សុផល ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ ចុះថ្ងៃទី១៩ ខែ១១ ឆ្នាំ១៩៩៣ របស់តុលាការខេត្តកណ្ដាល ។

២-ទណ្ឌិតឈ្មោះ ឈុន សុខឡេង ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់៧ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៨ ចុះថ្ងៃទី១២ ខែ៥ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកណ្ដាល ។

៣-ទណ្ឌិតឈ្មោះ សៀង ឡូត ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២២ ចុះថ្ងៃទី២០ ខែ៥ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកណ្ដាល។

៤-ទណ្ឌិតឈ្មោះ ពេញ គង់ ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩"ក" ចុះថ្ងៃទី១១ ខែ៤ ឆ្នាំ១៩៩៦ របស់តុលាការខេត្តកណ្ដាល ។

៥-ទណ្ឌិតឈ្មោះ ធួន ម៉ិនថន ហៅ គួត គ្រុខ ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤២"ក" ចុះថ្ងៃទី២៧ ខែ១០ ឆ្នាំ១៩៩៥ របស់តុលាការខេត្តកណ្ដាល ។

៦-ទណ្ឌិតឈ្មោះ គិន នួន ហៅ ស៊ីម៉ុនថានួន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី២៣ ខែ១១ ឆ្នាំ១៩៩៣ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៧-ទណ្ឌិតឈ្មោះ សុខ អៅ ហៅ ឈិនឡុង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី២២ ខែ១១ ឆ្នាំ១៩៩៣ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៨-ទណ្ឌិតឈ្មោះ គួន ស៊ីន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩ ចុះថ្ងៃទី២៩ ខែ៦ ឆ្នាំ១៩៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៩-ទណ្ឌិតឈ្មោះ ចន រស់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ២៩ ចុះថ្ងៃទី២៩ ខែ៦ ឆ្នាំ១៩៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១០-ទណ្ឌិតឈ្មោះ រឿន ឌី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ២៦ ចុះថ្ងៃទី១៣ ខែ០២ ឆ្នាំ១៩៩៦ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១១-ទណ្ឌិតឈ្មោះ ឈុង ទ្រុះ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី២៩ ខែ៦ ឆ្នាំ១៩៩៣ របស់តុលាការខេត្តកណ្តាល ។

១២-ទណ្ឌិតឈ្មោះ ឌួច ឆាត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ២៤ ចុះថ្ងៃទី២២ ខែ៦ ឆ្នាំ១៩៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ។

១៣-ទណ្ឌិតឈ្មោះ ជួន នី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៦ ចុះថ្ងៃទី២៥ ខែ៧ ឆ្នាំ១៩៩៤ របស់តុលាការ ខេត្តកំពត ។

១៤-ទណ្ឌិតឈ្មោះ ជៀន រុន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៣ ចុះថ្ងៃទី២១ ខែ៧ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកំពត ។

១៥-ទណ្ឌិតឈ្មោះ ផាត់ សេង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ ចុះថ្ងៃទី២១ ខែ៦ ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពត ។

១៦-ទណ្ឌិតឈ្មោះ នុច ពៅ ហៅ ខែម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៣ឆ្នាំ តាមអំណាចសាលក្រមលេខ៤០ ចុះថ្ងៃទី១០ ខែ៩ ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពត។

១៧-ទណ្ឌិតឈ្មោះ សេត ឡូច ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ ចុះថ្ងៃទី១០ ខែ១០ ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពត ។

១៨-ទណ្ឌិតឈ្មោះ ដួង ញឹម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ ចុះថ្ងៃទី១២ ខែ៩ ឆ្នាំ១៩៩៣ របស់តុលាការខេត្តកំពត ។

១៩-ទណ្ឌិតឈ្មោះ សាន់ តី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី៣០ ខែ៣ ឆ្នាំ១៩៩៦ របស់តុលាការខេត្តតាកែវ ។

២០-ទណ្ឌិតឈ្មោះ ឌួង ឈាង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ ចុះថ្ងៃទី២៩ ខែ៣ ឆ្នាំ១៩៩៥ របស់តុលាការខេត្តតាកែវ ។

២១-ទណ្ឌិតឈ្មោះ ឃួន គន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៧ ចុះថ្ងៃទី១៦ ខែ១០ ឆ្នាំ១៩៩៦ របស់តុលាការខេត្តតាកែវ។

២២-ទណ្ឌិតឈ្មោះ សាត់ គុត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី២៤ ខែ៥ ឆ្នាំ១៩៩៥ របស់តុលាការខេត្តតាកែវ ។

២៣-ទណ្ឌិតឈ្មោះ ឆេង ហាត់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី៧ ខែ១២ ឆ្នាំ១៩៩៤ របស់តុលាការខេត្តតាកែវ ។

២៤-ទណ្ឌិតឈ្មោះ ធុញ វិច ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី១៥ ខែ៦ ឆ្នាំ១៩៩៥ របស់តុលាការខេត្តតាកែវ ។

២៥-ទណ្ឌិតឈ្មោះ ដួង វេង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី២៩ ខែ៦ ឆ្នាំ១៩៩៥ របស់តុលាការខេត្តតាកែវ ។

២៦-ទណ្ឌិតឈ្មោះ ជីម ឌិន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់២ឆ្នាំ តាមអំណាចសាលក្រមលេខ ៤ "ឃ" ចុះថ្ងៃទី២៦ ខែ១២ ឆ្នាំ១៩៩៦ របស់តុលាការខេត្តព្រៃវែង ។

២៧-ទណ្ឌិតឈ្មោះ ដួង សោម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥ ចុះថ្ងៃទី១៣ ខែ០១ ឆ្នាំ១៩៩៥ របស់តុលាការ ខេត្តព្រៃវែង។

២៨-ទណ្ឌិតឈ្មោះ ឃុត ជយ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៣ឆ្នាំ តាមអំណាចសាលក្រមលេខ១៥ "ក" ចុះថ្ងៃទី០១ ខែ៨ ឆ្នាំ១៩៩៦ របស់តុលាការខេត្តព្រៃវែង ។

២៩-ទណ្ឌិតឈ្មោះ អំ ថេង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ ចុះថ្ងៃទី២១ ខែ០២ ឆ្នាំ១៩៩៦ របស់តុលាការខេត្តតាកែវ ។

៣០-ទណ្ឌិតឈ្មោះ ឈិន ឆាំ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី២៩ ខែ៦ ឆ្នាំ១៩៩៥ របស់តុលាការខេត្តតាកែវ ។

៣១-ទណ្ឌិតឈ្មោះ ម៉ុច ឆេង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ២២ ចុះថ្ងៃទី២៩ ខែ៦ ឆ្នាំ១៩៩៥ របស់តុលាការខេត្តតាកែវ ។

៣២-ទណ្ឌិតឈ្មោះ អ៊ុម ឆ្វំ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ ចុះថ្ងៃទី៦ ខែ៨ ឆ្នាំ១៩៩៣ របស់តុលាការខេត្តតាកែវ ។

មាត្រា ៥.-ត្រូវលើកលែងទោសអោយទណ្ឌិតចំនួន ៥នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយនាមខាងក្រោម :

១-ទណ្ឌិតឈ្មោះ រំហេម ខាន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី២១ ខែ០២ ឆ្នាំ១៩៩៤ របស់តុលាការខេត្តកណ្តាល។

២-ទណ្ឌិតឈ្មោះ ក្រូច ទ្រី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៩ "ក" ចុះថ្ងៃទី២៤ ខែ១០ ឆ្នាំ១៩៩៥ របស់តុលាការខេត្តកណ្តាល ។

៣-ទណ្ឌិតឈ្មោះ ឆ្លាយ ផៃនន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៣ ឆ្នាំ តាមអំណាចសាលក្រមលេខ៣៦ ចុះថ្ងៃទី៣ ខែ៩ ឆ្នាំ១៩៩៥ របស់តុលាការខេត្តតាកែវ។

៤-ទណ្ឌិតឈ្មោះ អ៊ុខ លី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៥ ចុះថ្ងៃទី២១ ខែ៧ ឆ្នាំ១៩៩៣ របស់តុលាការខេត្តតាកែវ ។

៥-ទណ្ឌិតឈ្មោះ គឹម វិចម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ២ ចុះថ្ងៃទី២៨ ខែ១០ ឆ្នាំ១៩៨៧ របស់តុលាការខេត្តតាកែវ ។

មាត្រា ៦.-ព្រះរាជក្រឹត្យនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៧.-ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេចជាស្ថាពរ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

ព្រះរាជក្រឹត្យ ជស/រកត ១១៩៧.២៨៦

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត ឲិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * *

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តមឧត្តមសេនីយ៍ទោ ជា ម៉ន ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស.រកត ១១៩៧.២៨៨

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * *

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ។

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តមឧត្តមសេនីយ៍ត្រី ឆាន ផាត ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹតនេះអោយបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ព្រះរាជក្រឹត្យ នស/រកត/១១៩៧/២៤៨

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរ័ត្ន និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * *

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល កម្ពុជា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម ជ៉ន់ ចន្ធា ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស.រកត ១១ ៩៧.២៨៩

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * *

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម ស៊ ហួរ ជា អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស.រកត ១១ ៩៧.២៥០

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

*****

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-យោងតាមសំណើរបស់សនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម ទី តាឃី ជាអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស.រកត ១១ ៩៧.២៥១

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * *

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃ ទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម ជុំ សម្បឿន ជា អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ មានឋានន្តរស័ក្តិ ជា ឧត្តមសេនីយ៍ទោ ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

# ព្រះរាជក្រឹត្យ ជស.រកត ១១. ៩៧.២៥២

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

*****

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម ហ៊ូ តាំងអេង ជា នាយកវិទ្យាស្ថានជាតិស្ថិតិ ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

# ព្រះរាជក្រឹត្យ ជស.រកត ១១ ៩៧.២៨៣

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * *

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៧

## ត្រាស់បង្គាប់

**មាត្រា ១.-** តែងតាំងឯកឧត្តម ស៊ុំ សន្និសិទ្ធ ជាអគ្គនាយកនៃអគ្គនាយកដ្ឋានផែនការ ។

**មាត្រា ២.-** នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៧៥ អនក្រ.បក
### ស្តីពីការផ្ទេរឥណទាន

✧ ✧ ✧ ✧ ✧

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ស.រកត ០៨៩៧.១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការបង្កើតក្រស[illegible]ដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/[illegible] ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០១ នស៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧

-បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ចំណូល និងចំណាយថវិកាតាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៤ និងប្រកាស ស្តីពីការកែប្រែ និងបំពេញបន្ថែមជាបន្តបន្ទាប់មាន: លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៩៤ លេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៩៥ លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៥ លេខ៣៣៦ ប្រក.សហវ.ថ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៥ លេខ ០៧១ ប្រក.សហវ.ថ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៩៦ និងលេខ ៨០១ សហវ.ថ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៦

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១.- ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ៤១(ចំណាយឥតគ្រោងទុក) នៃ ថវិការដ្ឋចំនួន ១.៥០០ លានរៀល(មួយពាន់ប្រាំរយលានរៀលគត់) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងជួសជុលតូច) ចំនួន ១.០០០ លានរៀល (មួយពាន់លានរៀល)ជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) ចំនួន ៥០០ លានរៀល (ប្រាំរយលានរៀល) ក្នុងវង់ថវិកា របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ។

មាត្រា ២.- ឥណទានក្នុងមាត្រា ១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់បំពេញតំរូវការចំណាយជូនរាជរដ្ឋាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

មាត្រា ៣.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

# អនុក្រឹត្យលេខ ៣៦ អនក្រ.បក

## ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ

## តំបន់ព្រែកទឹកសាប នៅខេត្តព្រះសីហនុ

*****

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីកិច្ច ការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានឃើញក្រឹត្យ-ច្បាប់លេខ ៣៥ ក្រច. ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៧

## សំរេច

មាត្រា ១.-តំបន់ព្រែកទឹកសាប ជាប្រភពតែមួយគត់សំរាប់ធានានិរន្តភាព នៃការអភិវឌ្ឍន៍ក្រុងព្រះសីហនុ ដែលកំពុងរងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ហើយចាំបាច់ត្រូវរៀបចំថែរក្សាការពារអោយមានស្ថេរភាពឡើងវិញ ។

មាត្រា ២.-តំបន់ព្រែកទឹកសាប ជាតំបន់ព្រៃបំរុងទុករបស់រដ្ឋ សំរាប់ផលប្រយោជន៍សាធារណៈ ស្ថិតនៅលើចំណុចប្រសព្វគ្នានៃខ័ណ្ឌមិត្តភាព ស្ទឹងហាវ និងខ័ណ្ឌព្រៃនុប ដូចមានកំណត់ក្នុងផែនទីខ្នាត 1:50.000 ផែនទីហានលេខាចំណាងជើង ក្រុងព្រះសីហនុ ។ លេខសំគាល់ N° 5.730. III សេរី L7016 ភ្ជាប់មកជាមួយនេះ ។ ទីតាំងនៃតំបន់ព្រែកទឹកសាបនេះមានផ្ទៃដីទំហំ 6.202 ហ.តស្ថិតនៅត្រង់ចន្លោះខ្សែស្របទី 10°30' និង 10° នៃរយៈទទឹងខាងជើង និងខ្សែបណ្តោយទី 103°30' និង 104° នៃរយៈបណ្តោយខាងកើត ។

មាត្រា ៣.- មិនអនុញ្ញាតអោយមានការអភិវឌ្ឍន៍ផ្នែក វារីវប្បកម្ម វិស័យទេសចរណ៍ វិស័យឧស្សាហកម្ម រួមទាំងកសិ-ឧស្សាហកម្ម ដែលជាប្រភពនៃការបំពុលទឹកក្រោមដី និងលើដី ។

មាត្រា ៤.- ចំពោះសកម្មភាពដែលកំពុងដំណើរការបច្ចុប្បន្ន ទាមទារអោយមានការវាយតម្លៃហេតុប៉ះពាល់ពាល់បរិស្ថាន ។

មាត្រា ៥.- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានរុក្ខាប្រមាញ់ មានភារកិច្ច :

-ថែរក្សាការពារព្រៃធម្មជាតិ សត្វព្រៃ និង ដាំឈើឡើងវិញ ។

-គ្រប់គ្រងការពារធនធានទឹក ដោយសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

មាត្រា ៦.- រាល់បទបញ្ញត្តិទាំងឡាយផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង អភិបាលក្រុងព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

# អនុក្រឹត្យលេខ ២១៨ អនក្រ.តត

## ស្ដីពី

## ការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

## សំរេច

មាត្រា ១.-ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនអ្នកឯកទេសអ៊ីរ៉ុបចំនួន ១៤ រូប ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត និងបច្ចេកទេស ក្នុងការអនុវត្តន៍កម្មវិធីទ្រទ្រង់ផ្នែកបឋមសិក្សា "PASEC" ចាប់ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ១៩៩៧ ដែលមានទំហំទឹកប្រាក់ ១៨ លានដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ :

ក.មេដាយមាសស្ថាបនាជាតិ :

| | |
|---|---|
| ១-លោក Jean Michel Le Pecq | នាយកកម្មវិធី |
| ២-លោក Gérard Renou | ទីប្រឹក្សាបច្ចេកទេស |

៣-លោក François Famia នាយករងកម្មវិធី

៤-លោក Jacques Molinari នាយករងកម្មវិធី

ខ.រមេជាយម្ចាត់ស្ថាបនាជាតិ :

១-កញ្ញា Myriam Bassinot ជំនាញការ

គ.រមេជាយសិទ្ធស្ថាបនាជាតិ :

១-លោក ErickGarnier ជំនួយការបច្ចេកទេស

២-លោក Rolland Raynaud ជំនួយការបច្ចេកទេស

៣-កញ្ញា Marie Christine Uguen ជំនួយការបច្ចេកទេស

៤-កញ្ញា Sokha Chéng ជំនួយការបច្ចេកទេស

៥-លោក Vincent Rzemien ជំនួយការបច្ចេកទេស

៦-លោកស្រី Mady Ridel ជំនួយការបច្ចេកទេស

៧-លោកស្រី Kim Uch ជំនួយការបច្ចេកទេស

៨-កញ្ញា Satwant Kaur ជំនួយការបច្ចេកទេស

៩-កញ្ញា Béatrice Montariol ជំនួយការបច្ចេកទេស

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

## អនុក្រឹត្យលេខ ២០៩ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

## សំរេច

មាត្រា ១.-ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិជូនលោកឧកញ៉ា សៅ ភារីម្មន្តី ហៅ យ៉ាត ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនចំនួន ៤៨[illegible] ដុល្លាអាមេរិក សំរាប់ សាងសង់ផ្ទះចំនួន ១៦០ ខ្នង ធ្វើពីឈើ ប្រក់ក្បឿង និងស័ង្កសី ជូនប្រជាពលរដ្ឋក្រីក្រ នៅក្នុងឃុំបុសមន ស្រុករំដួល ខេត្តស្វាយរៀង ។

មាត្រា ២.-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

អនុក្រឹត្យលេខ ២៦០ អនក្រ.តត

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

* * * * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០២/នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១.-តែងតាំងលោក អ៊ិន សារឿន ជា នាយកទីចាត់ការគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួសលោក ស ឃួរ ដែលត្រូវបានតែងតាំងតម្លើងឋានៈ។

មាត្រា ២.-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ុង ហួត ហ៊ុន សែន

អនុក្រឹត្យលេខ ២២១ អនក្រ.តត

ស្តីពី

ការជូនមេដាយសហមេត្រី

*****

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាត

**សំរេច**

មាត្រា ១.-ត្រូវបានប្រគល់មេដាយ សេនាសហមេត្រីជូនលោកវរសេនីយ៍ឯក VICTOR G RAPHAEL សេនានុពន្ធយោធាសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំប្រឹងប្រែង យ៉ាងសកម្ម ក្នុងការលើកស្ទួយចំណងមិត្តភាព និង សហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា សហរដ្ឋអាមេរិក ។

មាត្រា ២.-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

-អនុក្រឹត្យលេខ ២២២ អនក្រ.តត -

អនុក្រឹត្យលេខ ២២២ អនក្រ.តត
ស្ដីពី
ការជូនមេដាយសហមេត្រី

* * * * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

មាត្រា ១.-ត្រូវបានប្រគល់មេដាយ សេនាសហមេត្រីជូនលោកអនុសេនីយឯក AMJAURY de SAINT JULIEN ជំនួយការយោធាបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានមកបំពេញបេសកកម្មនៅកម្ពុជាប្រកបដោយស្នាដៃល្អប្រសើរ ក្នុងការជួយឧបត្ថម្ភដល់កងយោធពលខេមរភូមិន្ទ និង ការលើកស្ទួយទំនាក់ទំនង មិត្តភាពសហប្រតិបត្តិការទ្វេភាគី ។

មាត្រា ២.-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៧*

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

## អនុក្រឹត្យលេខ ២២៣ អនក្រ.តត
## ស្តីពី
## ការជូនមេដាយ សហមេត្រី

* * * * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពី ការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

### សំរេច

**មាត្រា ១.**-ត្រូវបានប្រគល់មេដាយសេនាសហមេត្រីជូនលោកវរសេនីយ៍ឯក YUKTAYANA TJUI-TRAWASITA សេនានុពន្ធយោធាឥណ្ឌូណេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបាន មកបំពេញបេសកកម្មនៅកម្ពុជា ប្រកបដោយស្នាដៃល្អប្រសើរ ក្នុងការជួយឧបត្ថម្ភដល់កង យោធពលខេមរភូមិន្ទ និងការលើកស្ទួយទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការទ្វេភាគី ។

**មាត្រា ២.**-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

## អនុក្រឹត្យលេខ ២២៨ អនក្រ.តត
## ស្ដីពី
## ការតែងតាំងមន្ត្រីរាជការ

* * * * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៨៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងផែនការ

-យោងតាមសំណើរបស់ក្រសួងផែនការ

### សំរេច

មាត្រា ១.-ត្រូវបានតែងតាំងមន្ត្រីរាជការ នៃក្រសួងផែនការដូចមានរាយនាមខាងក្រោម :

១-លោក ជិន ណេង ជាអគ្គាធិការរង

២-លោក វ៉ែត សៀវគីមសេង ជាអគ្គាធិការរង

៣-លោក លីវ លីមហាង ជាអគ្គាធិការរង

៤-លោក ហ៊្វី ហួរ ជាអគ្គាធិការរង

៥-លោក សន ស៊ីថន ជានាយករងនៃវិទ្យាស្ថានជាតិស្ថិតិ

៦-លោកស្រី ហ៊ាង សៀវគលី ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ

៧-លោក ខល្វ សាម៉ុន ជាប្រធាននាយកដ្ឋានបុគ្គលិក

៨-លោក តោះ សំអុស ជាប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

៩-លោក កែវ សម្បត្តិ ជាប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ

១០-លោក ហ៊ីង ចំនួមន្តា ជាប្រធាននាយកដ្ឋានវិនិយោគ

១១-លោក ផាន់ ហួរ ជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

១២-លោក ខៀវ សារី ជាប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច

១៣-លោក សេង ស៊ឿន ជាប្រធាននាយកដ្ឋានស្ថិតិប្រជារាស្ត្រ ជំរឿននិងអង្កេត

១៤-លោកស្រី ឯម សារឿន ជាប្រធាននាយកដ្ឋានស្ថិតិ សេដ្ឋកិច្ច

១៥-លោក សោម សេរីវុឌ្ឍ ជាប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច

១៦-លោកស្រី ខៀវ មូរី ជាប្រធាននាយកដ្ឋានផែនការ សង្គមកិច្ច

មាត្រា ៦.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៨៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ុង ហួត ហ៊ុន សែន

# III-ការងារបណ្តាក្រសួង

## ១-ទីស្តីការគណៈរដ្ឋមន្ត្រី

ប្រកាស

*រាជធានីភ្នំពេញ.ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧*

### ប្រកាសលេខ ១៥៥ ប្រក

### ស្តីពីការតែងតាំងមន្ត្រីរាជការ

✧ ✧ ✧ ✧ ✧

### សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤

-បានឃើញការចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងសមត្ថភាពរបស់មន្ត្រីរាជការ

**សំរេច**

**ប្រការ ១** : តែងតាំងលោក ឈៀង តែចឡាយ ជាអនុប្រធាននាយកដ្ឋានបុគ្គលិក នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ២** : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**សុខ អាន ណាគី តាន់**

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

*រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧*

ប្រកាសលេខៈ ១០១៧ ឧក.ប្រក

*****

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ២១៦៨/៩៧ក.អ.ក ចុះថ្ងៃទី២២ ខែ០៧ ឆ្នាំ១៩៩៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-បានឃើញលិខិតអនុញ្ញាតអោយសាងសង់របស់សាលាក្រុងភ្នំពេញលេខ ៤២២២ សអ.ស ចុះថ្ងៃទី១១.១២.៩៦

-បានឃើញលិខិតលេខ២៤៣៩ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៧ របស់មន្ទីររៀបចំក្រុង និងសំណង់

-យោងពាក្យស្នើរបស់ក្រុមហ៊ុន អិលវ៉ាយ អេស ភីធីអ៊ី អិលធីឌី ចុះថ្ងៃទី១៦.១០ ឆ្នាំ១៩៩៧

### សម្រេច

ប្រការ ១.-អនុញ្ញាតអោយក្រុមហ៊ុន អិល វ៉ាយ អេស ភីធីអ៊ី អិលធីឌី ( L.Y.S PTE.,LTD តំណាងដោយលោក CHOA YAK THIU សញ្ជាតិសិង្ហបុរី ភេទប្រុស អាយុ ៤៧ ឆ្នាំ អាស័យដ្ឋាន BLK 168 BUKIT BATOK BATOK WEST # 03 265 23265 SINGAPORE កាន់លិខិតឆ្លងដែនលេខ S 2097982H ចុះថ្ងៃទី 24.02.96 បង្កើត "រោងចក្រក្លាសេ" ដែលមានឈ្មោះថា "រោងចក្រក្លាសេ អិល វ៉ាយ អេស" មានទីតាំងស្ថិត នៅ ដីឡូត៍លេខ ៤៨ ផ្លូវជាតិលេខ ៤ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ។

ប្រការ ២.-ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាព បង្កើតរោងចក្រក្លាសេ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣.-ក្នុងកិច្ចដំណើការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណ-ភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ "ក្លាសេ ផ្លែឈើគ្រប់ប្រភេទ" ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើប្រ-កាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពូ សូធីរៈ

---

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧

**ប្រកាសលេខ ១០១៨ ឧក.ប្រក**

*****

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី០១ ខែវិច្ឆិការ ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ២៣២៤/៩៦ ក.វិ.ក ចុះថ្ងៃទី០១ ខែ១០ ឆ្នាំ១៩៩៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-បានឃើញលិខិតលេខ៣៥១៦ ឆត.ស ចុះថ្ងៃទី២១.១០.១៩៩៧ របស់សាលាក្រុងភ្នំពេញ ស្តីពីការឯកភាពអោយបើកសិប្បកម្មកាត់ដេរសំលៀកបំពាក់ ។

-យោងពាក្យស្នើរបស់ក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ស៊ីវ គិញ ( អ៊ិម អ៊ិហ្វ យី) ចុះថ្ងៃទី ២៧.១០ ឆ្នាំ១៩៩៧ ។

**សំរេច**

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ស៊ីវ គិញ (អ៊ិម អ៊ិហ្វ យី) (SUI QUINH GARMENT (MFG) LTD) តំណាងដោយលោក HO SIU CHEUNG សញ្ជាតិចិន (ហុងកុង) ភេទប្រុស អាយុ ៤៣ ឆ្នាំ អាស័យដ្ឋាន N°18,LOTUS ROAD.FAIR VIEW PARK.YUEN LONG HONG KONG កាន់លិខិតឆ្លងដែនលេខ P 620330851 ចុះថ្ងៃទី 19.4.1994 បង្កើត "រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ "មានឈ្មោះថា "រោងចក្រកាត់ដេរសំលៀកបំពាក់ស៊ីវ គិញ" មានទីតាំងស្ថិតនៅផ្ទះលេខ 58 E0.E1.E2 ផ្លូវលេខ 115 សង្កាត់បឹងព្រលិត ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ ផលិតនូវ "សំលៀកបំពាក់" ទៅតាមគំរូដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេចត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ

ប្រការ ៧ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ស៊ារ គិញ( អិម អិហ្វ យី ) ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៨ : ប្រកាសនេះមានអានុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពូ សុធីរ:

---

*រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧*

**ប្រកាសលេខ ១០១៩ ឧក.ប្រក**

*****

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ២៦៤៨/៩៦ គ.វិ.ក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ១៩៩៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-បានឃើញលិខិតលេខ ៤៤៧៧ ឆត.សរ ចុះថ្ងៃទី២៧.១១.១៩៩៥ របស់សាលាក្រុងភ្នំពេញស្តីពីការអនុញ្ញាតអោយប្តូរមុខសញ្ញាអាជីវកម្មពីកែច្នៃឈើ មកជាផលិតទឹកសណ្តែក

- យោងពាក្យស្នើរបស់ក្រុមហ៊ុន សួយ ហ្វុង ប៊ីវើរ៉េក និង ហ្វូដ អ៊ិនធើរប្រាយស៍ ចុះថ្ងៃទី០៥ ខែ១១ ឆ្នាំ១៩៩៧ ។

**សម្រេច**

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន សួយ ហ្វុង ប៊ីវើរ៉េក និង ហ្វូដ អ៊ិនធើរប្រាយស៍ (SUI FENG BEVERAGE & FOOD ENTERPRISES CO.,LTD) តំណាងដោយអ្នកស្រី LU ZHAO HUI សញ្ជាតិចិន ភេទស្រី អាយុ ៤៣ ឆ្នាំ អាស័យដ្ឋាន №16.ZILAI STREET,NANHUAZ HONG ROAD GUANGZHOU CHINA កាន់លិខិតឆ្លងដែនលេខ P 2922156 ចុះថ្ងៃទី 29.05.1996 បង្កើត "រោងចក្រផលិតទឹកសណ្ដែក" មានឈ្មោះថា "រោងចក្រផលិតទឹកសណ្ដែក សួយ ហ្វុង" មានទីតាំងស្ថិតនៅឡូត៍លេខ ៧៩៤ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាពបង្កើតរោង ចក្រផលិតទឹកសណ្ដែក ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន គុណភាពផលិតផល និងអនាម័យ ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សា ហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវ "ទឹកសណ្ដែក" ទៅតាមគំរូ និងផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៦ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន សួយហ្វុងប៊ីវើរ៉េក និងហ្វូដអ៊ិនធើប្រាយស៍ ត្រូវអនុវត្តប្រកាសនេះតាមមុខងាររៀងៗខ្លួន។

ប្រការ ៧ : ប្រកាសនេះមានអានុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពូ សុធីរៈ

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

**ប្រកាស**

*រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧*

**ប្រកាសលេខ ១៧១ ប្រ.ក**

**ស្តីពី**

**ការបង្កើតមជ្ឈមណ្ឌលព័ត៌មានវិទ្យាទេសចរណ៍**

TECHNOLOGY INFORMATION CENTER

❖ ❖ ❖ ❖ ❖

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងទេសចរណ៍

-បានឃើញអនុក្រឹត្យលេខ ២០/អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពី ការរៀបចំ និងការ ប្រព្រឹត្តិទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន.

-បានឃើញអនុក្រឹត្យលេខ ៣៤/អនក្រ.បក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងទេសចរណ៍

-យោងតាមសំណូមពរ នៃការលើកកំពស់ពត៌មានវិទ្យា វិស័យទេសចរណ៍

-តាមសំណើរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានទេសចរណ៍

**សំរេច**

**ប្រការ ១** ត្រូវបានបង្កើត មជ្ឈមណ្ឌលពត៌មានវិទ្យាទេសចរណ៍ Technology Information Center ចំណុះអគ្គនាយកដ្ឋានទេសចរណ៍ ដែលមានឋានៈស្មើនឹងការិយាល័យ ។

**ប្រការ ២ :** មជ្ឈមណ្ឌលពត៌មានវិទ្យាទេសចរណ៍ មានតួនាទីដឹកនាំ គ្រប់គ្រង ព្រមទាំងត្រួតពិនិត្យ ស្របតាមច្បាប់ជាធរមាន ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងប្រសិទ្ធភាព នូវរាល់ពត៌មានវិទ្យា ក្នុងវិស័យទេសចរណ៍ ។

**ប្រការ ៣ :** មជ្ឈមណ្ឌលពត៌មានវិទ្យាទេសចរណ៍ មានភារកិច្ចទំនាក់ទំនងជាមួយ អង្គការ ស្ថាប័នរដ្ឋ និង ឯកជននានាដើម្បីធ្វើការប្រមូលផ្តុំ ផលិត មធ្យោបាយពត៌មាននានា និងសហការ ក្នុងការ ឃោសនាផ្សព្វផ្សាយនូវរាល់ពត៌មានទាំងឡាយ ដែលបំរើអោយវិស័យទេសចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤ :** អគ្គនាយក នៃអគ្គនាយកដ្ឋានទេសចរណ៍ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវអនុវត្តតាមប្រកាស នេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ម៉ៅ ទូន

## ៤-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

### សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ១៩៩៧

### សេចក្តីសំរេចលេខ ៦៣៨ សសរ.មស.ក្រខ
### ស្តីពីការបែងចែកនិស្សិតចំនួន ៥៨ នាក់
### ដែលទើបបញ្ចប់ការសិក្សាពីសកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

* * * * *

### រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤ ៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤ ៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦ ២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៨៩៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-យោងលិខិតលេខ ៩០៤ សជណ ជក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

**សំរេច**

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់បរិញ្ញាបត្រសិល្បៈផ្នែកសូនរូបចំនួន ៣១ នាក់ និងថ្នាក់បរិញ្ញាបត្រសិល្បៈ ផ្នែកបុរាណវិទ្យាចំនួន ២៧ នាក់ ដែលបានបញ្ចប់ការសិក្សា ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ត្រូវបានបែងចែកអោយទៅបំរើការងារ នៅក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដូចមានក្នុងតារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចនេះ ។

ប្រការ ២ : ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និងផ្តល់បៀវត្សជូនសាមីជនចាប់ពី ថ្ងៃដែលបានចូលបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ប្រាត់ សួខ**

តារាងឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ៦៣៨ សសរ មស.ក្រ ចុះថ្ងៃទី ២១ ខែ១១ ឆ្នាំ១៩៩៧

ស្តីពីការបែងចែកនិស្សិតចំនួន ៥៨ នាក់ ដែលទើបបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃ ខែ ឆ្នាំ កំណើត | អង្គភាពដើម | មុខជំនាញបច្ចេកទេស | កំរិតបណ្តុះបណ្តាល | កំរិតបៀវត្ស | អង្គភាពចូលបំរើការងារ |
|---|---|---|---|---|---|---|---|---|
| ១ | គីម និប៉ុណ្ណា | ប | ០២-១២-៦៩ | សិស្ស | គំនូរទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ២ | ខឹម ពិន | ប | ២៥-៣-៦៧ | សិស្ស | គំនូរទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ៣ | គ្រីន សុខឡា | ប | ០៧-៥-៦៨ | សិស្ស | គំនូរទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ៤ | គយ ប៊ួយ | ប | ០៣-៤-៧១ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ៥ | ចាន់ ជ្រោយ | ប | ០៣-៤-៦៩ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ៦ | ចួយ ពិសី | ប | ១៤-៣-៧០ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ៧ | ជួន ចាបូរ៉ា | ប | ២០-៧-៦៧ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ៨ | ឈឹម សុធី | ប | ១០-០១-៦៩ | សិស្ស | គំនូរទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ៩ | ញៀម ប្ញូរិន | ប | ០៨-៨-៦៨ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ១០ | នួន គីមណាន់ | ប | ០៣-០២-៦៨ | សិស្ស | គំនូរទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ១១ | ប៉ាក សុវណ្ណ | ប | ១២-១២-៧០ | សិស្ស | គំនូរទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ១២ | ផន នី | ប | ០១-០២-៦៩ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ១៣ | ពៅ វ៉ា | ប | ០៩-៥-៧០ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០ខ១ ៤ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៤ | ម៉ុន ថា | ប | ០៧-១០-៦៩ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ១៥ | ម៉ក់ រ៉េមីសា | ប | ០៥-៩-៧០ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ១៦ | យឹម ផលលៀង | ប | ១៦-៥-៦៧ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ១៧ | លី ជុយ | ប | ០៣-១២-៧១ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ១៨ | លី សុផាត | ប | ៣០-១១-៦៨ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ១៩ | លី សុផល | ប | ០១-០១-៦២ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ២០ | លាប់ សុខលី | ប | ០៦-៧-៦៨ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ២១ | សយ សុវណ្ណា | ប | ០៤-៤-៦៨ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ២២ | សាន សារិទ្ធ | ប | ០៥-០២-៦៨ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ២៣ | ស សំអុន | ប | ១៥-៨-៧១ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ២៤ | សា ពិសិដ្ឋ | ប | ០៤-០១-៦៨ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ២៥ | ហួត សុធី | ប | ១៥-៥-៦៨ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ២៦ | ឡាយ ម៉ៅ | ប | ០១-៥-៦៨ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ២៧ | អ៊ុក ទូច | ប | ០១-១០-៧០ | សិស្ស | គំនូរទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ២៨ | អ៊ី ច័ន្ទណារ៉ាក់ | ប | ០៥-៥-៦៨ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |
| ២៩ | អឿ សុវណ្ណារ៉ា | ប | ០១-៥-៦៦ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្បៈ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣០ | អឿ សុវណ្ណរិទ្ធ | ប | ០៥-១១-៦៧ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៣១ | អ៊ឹម កក្កិកា | ប | ២៤-៣-៦៩ | សិស្ស | ចំលាក់ទំនើប | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៣២ | កែវ ដាលីន | ស | ២១-៣-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៣៣ | គង់ វីរៈ | ប | ១២-១២-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៣៤ | គិម សេតារ៉ា | ប | ១១-០១-៧០ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៣៥ | គី យ៉ាលីប | ប | ២៤-១២-៥១ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៣៦ | គិម មិញ | ប | ១២-១២-៧១ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៣៧ | គួ រិត | ប | ១០-៩-៧១ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៣៨ | ច័ន្ទ សម្បត្តិ | ប | ០១-០១-៦៩ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៣៩ | ជា នាង | ប | ០៥-០២-៧៣ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៤០ | ឈឹម សុមុនី | ប | ២៥-១២-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៤១ | តាន់ សុផល | ប | ០៧-៣-៧១ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៤២ | ថោង ប៊ុនធឿន | ប | ០៩-៧-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៤៣ | ទា រ៉ាំង | ប | ០១-០២-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៤៤ | ទិវ សុផល | ប | ០១-០២-៧៣ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៤៥ | នៅ ចំរុង | ប | ០១-៣-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ I១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤៦ | ប្រាក់ សុវណ្ណារ៉ា | ប | ១០-៧-៧១ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៤៧ | ប្រាក់ ប៉ូរស្មី | ស | ០៩-៦-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៤៨ | ប្រាង្គ សុផល | ប | ០៦-៨-៦៧ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៤៩ | ផាន់ ណាតុំ | ប | ១៧-៣-៧០ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៥០ | យ៉ៅ ពា | ប | ០៧-៥-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៥១ | យិន រត្តនិន្ទរ៍ | ស | ១៣-៣-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៥២ | រស់ វិសុទ្ធ | ប | ០៦-៥-៦៩ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៥៣ | រ័ត្ន កេសរ៉ា | ប | ២០-០១-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៥៤ | លិម ហាក់ | ប | ០៨-៧-៧១ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៥៥ | សុក កាន់ណូរី | ប | ០១-១០-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៥៦ | ហង្ស ចន្ទសោភា | ស | ២៨-៦-៧១ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៥៧ | អ៊ា ដារិទ្ធ | ប | ១០-៤-៧៣ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |
| ៥៨ | អ៊ឹម សុខរិទ្ធី | ប | ៣០-៤-៧២ | សិស្ស | បុរាណវិទ្យា | មធ្យម | ៩០%ខ ។១ | ក្រសួង វប្បធម៌និងវិចិត្រសិល្ប: |

បានបញ្ឈប់បញ្ជីនេះត្រឹមចំនួនហាសិបប្រាំបី "៥៨" នាក់ប៉ុណ្ណោះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ប្រាក់ សុខ

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល